00351960

E40/2

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**Declassified to Public**
**06 September 2012**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / JUL / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance
សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ

## ប្រធានអង្គជំនុំជម្រះសាលាដំបូង

## ជូនចំពោះ

## លោក ការ សាវុត្ថ និងលោក François ROUX មេធាវីរបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ

**កម្មវត្ថុ៖** សំណើសុំកោះអញ្ជើញ មាស គឹមសៀវ (Meas Kimsieu) ឲ្យមកបង្ហាញខ្លួន (D14)
**ចំណាត់ថ្នាក់នៃឯកសារ៖** សម្ងាត់បំផុត

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ លោកបានស្នើសុំមកអង្គជំនុំជម្រះសាលាដំបូងឲ្យកោះអញ្ជើញ លោកស្រី មាស គឹមសៀវ (D14) ដែលជាម្ដាយរបស់ជនជាប់ចោទឲ្យមកបង្ហាញខ្លួន។ តាមរយៈសេចក្ដីសម្រេចចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានទទួលយល់ព្រមតាមសំណើនេះ ហើយក៏បានផ្អាកការវិនិច្ឆ័យទៅលើកាលានុវត្តភាពក្នុងការសម្រេចឲ្យមានវិធានការការពារដល់សាក្សីរូបនេះរហូតដល់ពេលដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានការវាយតំលៃលើហានិភ័យដែលធ្វើឡើង ដោយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ[1]។ ការវាយតំលៃដែលមានលក្ខណៈសម្ងាត់បំផុត ត្រូវបានភ្ជាប់មកជាមួយលិខិតនេះដើម្បីផ្ដល់ជូនជាព័ត៌មានដល់លោក[2]។ ឯកសារនេះជាធាតុផ្សំថ្មីមួយដែលតាមរយៈធាតុផ្សំនេះ វាច្បាស់ណាស់ថាការបង្ហាញខ្លួនជាយថាហេតុរបស់សាក្សី (D14)

[1] សេចក្ដីសម្រេចចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៩ ទាក់ទងទៅនឹងវិធានការការពារដែលបានស្នើសុំសម្រាប់សាក្សីនិងអ្នកជំនាញខ្លះ និងទាក់ទងទៅនឹងសំណើរបស់ភាគីដែលស្នើសុំឲ្យកោះអញ្ជើញសាក្សីនិងអ្នកជំនាញឲ្យបង្ហាញខ្លួន (ឯកសារ E40/1)។

[2] ឯកសារ E105។

អាចបណ្ដាលឲ្យមាននូវបញ្ហាលំបាកដែលអង្គជំនុំជម្រះសាលាដំបូងមិនបានគ្រោងទុកជាមុនទេរហូតមកទល់ពេលនេះ។

ដោយហេតុនេះហើយបានជា អង្គជំនុំជម្រះសាលាដំបូងចង់ដឹងឲ្យបានមុនថ្ងៃទី២២ ខែកក្កដាខាងមុខនេះ អំពីគោលជំហររបស់ក្រុមការពារក្ដីចំពោះសេចក្ដីសន្និដ្ឋានរបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញជាពិសេសថា តើក្រុមការពារក្ដីមានបំណងរក្សាសំណើសុំឲ្យលោកស្រី មាស គឹមសៀវ មកបង្ហាញខ្លួនដែរឬទេហើយនៅក្នុងករណីនេះ ចង់ដឹងពីហេតុផលជាក់លាក់ដែលយល់ថាការបង្ហាញខ្លួនរបស់លោកស្រីនេះគឺជាការចាំបាច់។

ភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

និល - ណុន